ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២៩៧/១៣-អេស៊ា ជ្រេហ្គួន (ហ្គាមេន)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ហែម ហួណារិទ្ធ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **រុន សារ៉ាយ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន អេស៊ា ជ្រេហ្គួន (ហ្គាមេន)**

អាសយដ្ឋាន ៖ ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៨៩ ៨៨ ០៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- កញ្ញា ជា សុខលី ប្រធានរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពកម្មករនិយោជិត**

អាសយដ្ឋាន ៖ ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៧២ ៨៤ ៧២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោក សន ប្រាក់ អគ្គលេខាធិការសហព័ន្ធសហជីពកម្មករនិយោជិត

២- លោក ហៃ សីហា អនុប្រធានសហព័ន្ធ

៣- លោក ដួត កុសល់ លេខាសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន អេស៊ា ដ្រេហ្គន ទាមទារឱ្យក្រុមហ៊ុនផ្តល់លុយបាយថែមម៉ោង ១ ម៉ោង ១០០០ រៀល។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ជូនទៅតាមច្បាប់កំណត់ឱ្យ។

២- ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន អេស៊ា ដ្រេហ្គន ទាមទារឱ្យក្រុមហ៊ុនកាត់លុយព្រីម (ប្រាក់រង្វាន់ធ្វើការទៀងទាត់) ជាសមាមាត្រ ពេលកម្មករឈប់មានធុរៈ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមច្បាប់(អនុវត្តតាមគោការណ៍កន្លងមក)។

៣- ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន អេស៊ា ដ្រេហ្គន ទាមទារឱ្យក្រុមហ៊ុនផ្តល់លុយស្នាក់នៅ ឬលុយធ្វើដំណើរចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនផ្តល់ជូនតាមច្បាប់កំណត់ឱ្យ (អនុវត្តតាមគោការណ៍កន្លងមក)។

៤- ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន អេស៊ា ដ្រេហ្គន សុំឱ្យក្រុមហ៊ុនផ្តល់លុយព្រីមចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ ក្រុមហ៊ុនសុំផ្តល់ជូនទៅតាមច្បាប់កំណត់ឱ្យ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម លេខ ១៤៦៨ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ ៖ ០០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពកម្មករនិយោជិត លេខ ២០៧/១៣ ស.ស.ក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីកម្មករនិយោជិត (ថ្នាក់ដឹកនាំសហជីពកម្មករនិយោជិត) នៃក្រុមហ៊ុន អេស៊ា ជ្រាហ្គន ទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានប្រសើរជូនកម្មករនិយោជិត។ ក្រោយពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១១ ចំណុច មិនសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ១៥ ចំណុច។ ចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១៤៦៨ កប/អក/វក. ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០១៣។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៤ ចំណុចនេះបន្ថែមទៀត ដោយភាគីទាំងពីរបានសះជានឹងគ្នាលើចំណុចវិវាទចំនួន ១ គឺចំណុចវិវាទទី២។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាទៅលើចំណុចវិវាទមិនសះជា ដែលនៅសល់មានចំនួន ០៣ ប៉ុណ្ណោះ គឺ ចំណុចវិវាទទី១, ទី៣និង ទី៤។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទដែលនៅសល់ខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ របស់នាយកក្រុមហ៊ុន អេស៊ា ជ្រេហ្គន ផ្ទេរសិទ្ធិជូនកញ្ញា ជា សុខលី ដើម្បីចូលរួមសម្របសម្រួល ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន អេស៊ា ជ្រេហ្គន (ហ្គាមេន) លេខ ៤៩៨៧ ពណ.ចបព ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។

៣- លក្ខន្តិកៈក្រុមហ៊ុន អេស៊ា ជ្រេហ្គន តំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម លេខ ៩៨៥/៥៩ ពណ. នតក.បព ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៤

ខ- ឯកសារបានទទួលពីភាគីនិយោជិត ៖

- លិខិតពឹងពាក់ និងផ្ទេរសិទ្ធិ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៣ របស់ថ្នាក់ដឹកនាំសហជីព កម្មករនិយោជិត និងកម្មករ កម្មការិនី បំរើការងារនៅរោងចក្រ អេស៊ា ដ្រេហ្គន ពឹងពាក់ និងផ្ទេរសិទ្ធិជូនប្រធានសហព័ន្ធសហជីពកម្មករនិយោជិតជួយចរចាជាមួយប្រធានក្រុមហ៊ុន។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេស៊ា ដ្រេហ្គន លេខ ១៤៦៨ កប/អក/វក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេស៊ា ដ្រេហ្គន ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១២៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១២៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន អេស៊ា ដ្រេហ្គន (ហ្កាមេន) (តទៅនេះហៅថា ក្រុមហ៊ុន អេស៊ា ដ្រេហ្គន) ជាក្រុមហ៊ុន ដែលមានសកម្មភាពចម្បងក្នុងការបោកគក់។ ក្រុមហ៊ុននេះបានចុះបញ្ជីពាណិជ្ជកម្ម ក្រោមលេខ Inv. ៦៥១ E/១៩៩៩ តាមរយៈវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម លេខ ៤៩៨៧ ពណ.ចបព. របស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១១។ នៅក្នុងវិញ្ញាបនបត្របញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈរបស់ក្រុមហ៊ុន សរសេរថា ក្រុមហ៊ុន "អេស៊ា ដ្រេហ្គន" ដែលមានលក្ខណៈផ្លូវការ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចប្រើពាក្យថា ក្រុមហ៊ុន "**អេស៊ា ដ្រេហ្គន**" ជំនួសឱ្យពាក្យថា "**អេស៊ា ដ្រាហ្គន**" ។ បច្ចុប្បន្ននេះ ក្រុមហ៊ុនជួលកម្មករនិយោជិតសរុបប្រមាណជា ១២០ នាក់។
- សហព័ន្ធសហជីពកម្មករនិយោជិត ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហព័ន្ធសហជីពកម្មករនិយោជិតបានទទួលលិខិតពឹងពាក់ និងផ្ទេរសិទ្ធិ ពីកម្មករចំនួន ០៣ នាក់ ឱ្យសហព័ន្ធសហជីពកម្មករ

THE ARBITRATION COUNCIL

និយោជិត ជួយចរចាជាមួយនិយោជករោងចក្រ អេស៊ា ជេវហ្គូន ដើម្បីដោះស្រាយនូវវិលក្ខខណ្ឌការងារមួយចំនួន ។

**ចំណុចវិវាទទី ០១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១ ម៉ោង ១០០០ រៀល**

- បច្ចុប្បន្ន ការអនុវត្តរបស់រោងចក្រ គឺនិយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០រៀល ក្នុងមួយថ្ងៃ។
- ភាគីទាំងពីរបានទទួលស្គាល់ថា ៖
  - ម៉ោងធ្វើការរបស់ក្រុមហ៊ុន ចែកចេញជា ២ ពេល ដូចខាងក្រោម ៖
    - ពេលព្រឹក ៖ ចាប់ពីម៉ោង ៦៖ ០០ នាទី ព្រឹក ដល់ម៉ោង ១១៖០០ នាទី ព្រឹក
    - ពេលរសៀល ៖ ចាប់ពីម៉ោង ១១៖៣០ នាទី ព្រឹកដល់ម៉ោង ២៖០០ នាទីរសៀល
  - បច្ចុប្បន្ន ក្រុមហ៊ុនបានបែងចែកការធ្វើការបន្ថែមម៉ោងជា ២ វគ្គ ដែល ៖
    - វគ្គទី១៖ ពីម៉ោង ២៖០០ នាទី ដល់ម៉ោង ៤៖០០ នាទី
    - វគ្គទី២៖ ពីម៉ោង ៤៖០០ នាទី ដល់ម៉ោង ៦៖០០ នាទី
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ជាធម្មតាច្បាប់កំណត់ឱ្យធ្វើការបន្ថែមម៉ោងត្រឹមតែ ២ ម៉ោង ក្នុងមួយថ្ងៃ។ ដោយឡែក ជាការអនុវត្តរបស់ក្រុមហ៊ុន ក្រុមហ៊ុនបានឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងដល់ទៅ ៤ ម៉ោង ក្នុងមួយថ្ងៃ។ ដោយមូលហេតុថា ក្រុមហ៊ុនបានឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងហួសពីអ្វីដែលច្បាប់បានកំណត់ ដូច្នេះ និយោជកគួរតែផ្តល់ប្រាក់ធ្វើការបន្ថែមម៉ោង ១ ម៉ោង ១០០០ រៀល នេះដល់កម្មករនិយោជិត ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - រោងចក្រដទៃទៀត បានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១ ម៉ោង ១០០០ រៀល
  - បើថែមតែ ២ ម៉ោង ក្នុងមួយថ្ងៃ ភាគីកម្មករនិយោជិតនឹងមិនធ្វើការទាមទារទេ។ ដោយឡែកចំពោះក្រុមហ៊ុននេះ និយោជកបានឱ្យកម្មករធ្វើការបន្ថែមម៉ោងចំនួន ៤ ម៉ោង ។
  - ភាគីនិយោជកបានឆ្លើយតបថា និយោជកបានអនុវត្តតាមច្បាប់ការងាររួចហើយ ។ ម្យ៉ាងវិញទៀតច្បាប់មិនមានចែងអំពីកាតព្វកិច្ចក្នុងការបន្ថែមប្រាក់ធ្វើការបន្ថែមម៉ោងទេ ។
- លើសពីនេះ ក្រុមហ៊ុនបានគោរពតាមគោលការណ៍ស្ម័គ្រចិត្ត នៃការធ្វើការបន្ថែមម៉ោង ។ កម្មករនិយោជិតធ្វើក៏បាន មិនធ្វើការបាន និយោជកមិនបង្ខំទេ ។
- ដូច្នេះ និយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ។

**ចំណុចវិវាទទី ០៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ ចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់

THE ARBITRATION COUNCIL

សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៨ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ៧ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺ ១៥ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត។

- ភាគីនិយោជកបានបញ្ជាក់ថា បច្ចុប្បន្ន និយោជកបានអនុវត្តទៅតាមច្បាប់ ដោយផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ ចំនួន ៧ ដុល្លារអាមេរិកក្នុងមួយខែ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - ក្រុមហ៊ុនដទៃទៀតបានផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ យ៉ាងហោចណាស់ ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ។
    - ថ្លៃផ្ទះឡើងថ្លៃ ទំនិញក៏ឡើងថ្លៃ ហើយតម្លៃធ្វើដំណើរតាមឡានឡើងថ្លៃដែរ។
    - បច្ចុប្បន្ន មិនមានតម្លៃឡាន ឬតម្លៃបន្ទប់ជួលណា ដែលមានតម្លៃ ៧ ដុល្លារអាមេរិកទេ
- ភាគីនិយោជកបានអះអាងថា មិនមែនរោងចក្រទាំងអស់សុទ្ធតែផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ ពី១០ ដុល្លារអាមេរិកឡើងទៅនោះទេ។ មានក្រុមហ៊ុនខ្លះក៏ផ្តល់ជូនដូចក្រុមហ៊ុនរបស់ខ្លួនដែរ គឺចំនួន ៧ ដុល្លារអាមេរិកក្នុងមួយខែ។
- និយោជកបានអះអាងទៀតថា បច្ចុប្បន្នក្រុមហ៊ុន ជាក្រុមហ៊ុនតូចតាច រកចំណូលបានតិចតួច ព្រមទាំងមានកម្មករនិយោជិតចំនួនតិចទៀតផង។ ក្រុមហ៊ុននេះ ជាក្រុមហ៊ុនដែលទទួលអីវ៉ាន់បន្តពីក្រុមហ៊ុនដទៃ ពេលខ្លះមានអីវ៉ាន់ ពេលខ្លះអត់។
- ដូច្នេះ និយោជកមិនមានលទ្ធភាពផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ។

**ចំណុចវិវាទទី ០៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់រង្វាន់ធ្វើការទៀងទាត់ (ប្រាក់ព្រីម) សរុបចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារថា ឱ្យនិយោជកបន្ថែមប្រាក់រង្វាន់ធ្វើការទៀងទាត់ ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ១០ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ។
- បច្ចុប្បន្ន និយោជកបានផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - បើក្រុមហ៊ុនតម្លើងប្រាក់រង្វាន់ធ្វើការទៀងទាត់នេះបានច្រើនជាងមុន នោះកម្មករនឹងមានជីវភាពល្អប្រសើរជាងមុន ព្រោះថាបច្ចុប្បន្នកម្មករជួបការលំបាក។
    - រោងចក្រដទៃទៀត ផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ពី ១២ ដុល្លារអាមេរិក រហូតដល់ ២០ ដុល្លារអាមេរិក។
- ភាគីនិយោជកអះអាងថា បច្ចុប្បន្នក្រុមហ៊ុន ជាក្រុមហ៊ុនតូច មានចំណូលមិនទៀងទាត់។
- ជាជំហររបស់និយោជក និយោជកមិនអាចតម្លើងតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី ០១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១ ម៉ោង ១០០០ រៀល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១ម៉ោង ១០០០រៀល ដល់កម្មករនិយោជិតដែរ ឬទេ?

យោងតាមចំណុចទី២ នៃសេចក្តីជូនដំណឹងលេខ ០៤៤ សកបយ. ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ចែងថា៖ *"កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពរនិយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយគតគិតថ្លៃ"* ។

តាមរយៈខ្លឹមសារនៃចំណុចទី២ នៃសេចក្តីជូនដំណឹងខាងលើ កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងតាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០ (ពីរពាន់)រៀល ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ក្នុងមួយថ្ងៃ ដោយមិនកំណត់ថា ធ្វើការថែមម៉ោងប៉ុន្មានម៉ោងនោះទេ ។

ក្នុងសំណុំរឿងនេះ ជាការអនុវត្តរបស់ក្រុមហ៊ុន និយោជកដែលផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០ រៀល ក្នុងមួយថ្ងៃដល់កម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា និយោជកបានបំពេញកាតព្វកិច្ចដែលមានចែងនៅក្នុងសេចក្តីជូនដំណឹងលេខ ០៤១/១១ ខាងលើរួចហើយ ។

ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានបទប្បញ្ញត្តិច្បាប់ស្តីពីការងារ អនុសញ្ញារួម កិច្ចព្រមព្រៀងណាមួយ រវាងភាគីទាំងពីរ បទបញ្ជាផ្ទៃក្នុង ឬការអនុវត្តកន្លងមក ដែលកំណត់ពីកាតព្វកិច្ចរបស់និយោជក ក្នុងការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១ ម៉ោង ១០០០ រៀល ជូនកម្មករនិយោជិតទេ។ ការទាមទារនេះ ជាការទាមទារប្រសើរជាងច្បាប់។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះ ជាវិវាទអំពីផលប្រយោជន៍។

ចំពោះវិវាទអំពីផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាដូចខាងក្រោម ៖

កថាខណ្ឌទី២ នៃមាត្រា៩៦ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុង មាត្រា៩៦ កថាខណ្ឌទី១ អនុសញ្ញារួមត្រូវធ្វើឡើងដោយព្រមព្រៀងគ្នារវាង ៖*

*ក. មួយចំណែកគឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយ ឬអង្គការច្រើនតំណាងឱ្យនិយោជក"* ។

*ខ. មួយចំណែកទៀត គឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត ។... ។"*

លើសពីនេះ ប្រការ៩ នៃប្រកាសលេខ ៣០៥ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ចែងថា ៖ *"សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំឱ្យនិយោជកធ្វើការចរចា អំពីអនុសញ្ញា*

*រួម ដែលអនុវត្តចំពោះកម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងឱ្យ ។ ក្នុងករណីនេះ និយោជកមាន កាតព្វកិច្ច ត្រូវតែធ្វើការចរចាជាមួយសហជីព ។"*

យោងតាមមាត្រា ៩៦ នៃច្បាប់ស្តីពីការងារ និងប្រការ ៩ នៃប្រកាសខាងលើ ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីពក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងវិវាទអំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"សេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធិភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ"*។

យោងតាមខ្លឹមសារនៃប្រការ ៤៣ នៃប្រកាសខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍ នឹងក្លាយជាអនុសញ្ញារួម ដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់ បាត់បង់សិទ្ធិក្នុងការធ្វើកូដកម្មដើម្បីទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស ឬសហជីពច្រើនរួមគ្នាទៅមានចំនួនសមាជិកលើសពីពាក់កណ្តាលនៃកម្មករនិយោជិតនៅក្នុងសហគ្រាស (សូមមើលសេចក្តីបង្គាប់ *លេខ ៨១/០៤-អេវើហ្គ្រីន ចំណុចវិវាទ ទី៤* និង*លេខ ៩៨/០៤-ហ្គ្រេត យូទៀន ចំណុចវិវាទទី៣*) ។

នៅក្នុងសំណុំរឿងលេខ ១៦៩/១១-ហ៊្វូរចុន ធីវ ត្រង់ចំណុចវិវាទទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ដោយសារសហជីពដែលនាំវិវាទការងារនោះ មកជាសហជីពដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ០២/១១-ពូយឿន ហេតុផលចំណុចវិវាទទី២* និង*លេខ ៦៦/១១-អ៊ិនហានស៊ុង ហេតុផលចំណុចវិវាទទី១*) ។

នៅក្នុងសំណុំរឿងនេះ មានតែកម្មករនិយោជិតចំនួន ០៣ នាក់ ដែលជាភាគីដើមបណ្តឹង បានពឹងពាក់ និងផ្ទេរសិទ្ធិឱ្យសហព័ន្ធសហជីពកម្មករនិយោជិតនាំសំណុំរឿងនេះមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មិនមានសហជីពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការនាំវិវាទ ដែលទាក់ទងនឹងផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណានោះទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១ ម៉ោង ១០០០ រៀល ដល់កម្មករនិយោជិត ។

THE ARBITRATION COUNCIL

**ចំណុចវិវាទទី ០៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៨ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ៧ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺ ១៥ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និង ថ្លៃស្នាក់នៅ ចំនួន ៨ ដុល្លារអាមេរិក ក្នុងមួយខែ លើទឹកប្រាក់ ៧ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺ ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែរ ឬទេ?

ចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ២៣០ កប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ កំណត់ថា៖ *"ផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ (ប្រាំពីរ) ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ"* ។

ក្នុងសំណុំរឿងនេះ ជាការអនុវត្តរបស់ក្រុមហ៊ុន និយោជកដែលផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា និយោជកបានបំពេញកាតព្វកិច្ច ដែលមានចែងនៅក្នុងសេចក្តីជូនដំណឹងលេខ ២៣០ ខាងលើរួចហើយ ។

លើសពីនេះទៅទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានបទប្បញ្ញត្តិច្បាប់ស្តីពីការងារ អនុសញ្ញារួមកិច្ចព្រមព្រៀងណាមួយ រវាងភាគីទាំងពីរ បទបញ្ជាផ្ទៃក្នុង ឬការអនុវត្តកន្លងមក ដែលកំណត់ពីកាតព្វកិច្ច របស់និយោជកក្នុងការបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៨ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ៧ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺ ១៥ ដុល្លារអាមេរិក ក្នុងមួយខែ នោះទេ។ ដូច្នេះ ការទាមទារនេះ ជាការទាមទារប្រសើរជាងច្បាប់ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះ ជាវិវាទអំពីផលប្រយោជន៍ ។

*(សូមមើលការបកស្រាយទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ នៅក្នុងហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១)* ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ ចំនួន ៨ ដុល្លារអាមេរិក ក្នុងមួយខែ លើទឹកប្រាក់ ៧ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺ ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ។

**ចំណុចវិវាទទី ០៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់រង្វាន់ធ្វើការទៀងទាត់ (ប្រាក់ព្រឹម)ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ១០ ដុល្លារអាមេរិក ដែលមានស្រាប់ សុរបគឺចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចបន្ថែមប្រាក់រង្វាន់ធ្វើការទៀងទាត់ (ប្រាក់ព្រឹម) ចំនួន ៥ ដុល្លារអាមេរិក លើទឹកប្រាក់ ១០ ដុល្លារអាមេរិក ដែលមានស្រាប់ សុរបគឺចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតដែរ ឬទេ?

ចំណុចទី២ នៃសេចក្តីជូនដំណឹង ២៣០ កប/ស.ជ.ណ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា៖ *"កម្មករនិយោជិតដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃនៃថ្ងៃធ្វើការក្នុង*

THE ARBITRATION COUNCIL

*ខែទីមួយ ដោយគ្មានវត្តមាន ត្រូវទទួលបានប្រាក់រង្វាន់យ៉ាងតិចចំនួន ១០ (ដប់) ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ ។..."*

នៅក្នុងសវនាការ ភាគីនិយោជកបញ្ជាក់ថា និយោជកបានផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែដល់កម្មករនិយោជិត ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា និយោជកបានបំពេញកាតព្វកិច្ចដែលមានចែងនៅក្នុងសេចក្តីជូនដំណឹងលេខ ២៣០/១២ ខាងលើរួចហើយ ។

ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានបទប្បញ្ញត្តិច្បាប់ស្តីពីការងារ អនុសញ្ញារួម កិច្ចព្រមព្រៀងណាមួយ រវាងភាគីទាំងពីរ បទបញ្ជាផ្ទៃក្នុង ឬការអនុវត្តកន្លងមក ដែលកំណត់ពីកាតព្វកិច្ចរបស់និយោជកក្នុងការបន្ថែមប្រាក់រង្វាន់ធ្វើការទៀងទាត់ ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ១០ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែជូនកម្មករនិយោជិតទេ ។ ការទាមទារនេះជាការទាមទារប្រសើរជាងច្បាប់ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះ ជាវិវាទអំពីផលប្រយោជន៍ ។

*(សូមមើលការបកស្រាយទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ នៅក្នុងហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១) ។*

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទារភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបន្ថែមប្រាក់រង្វាន់ធ្វើការទៀងទាត់ (ប្រាក់ព្រីម) ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ១០ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែជូនកម្មករនិយោជិត ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ០១ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង ១ ម៉ោង ១០០០ រៀល ដល់កម្មករនិយោជិត ។

**ចំណុចវិវាទទី ០៣ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបន្ថែមប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ ចំនួន ៨ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ៧ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺ ១៥ ដុល្លារអាមេរិកក្នុងមួយខែ ដល់កម្មករនិយោជិត ។

**ចំណុចវិវាទទី ០៤ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបន្ថែមប្រាក់រង្វាន់ធ្វើការទៀងទាត់ (ប្រាក់ព្រីម) ចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ លើទឹកប្រាក់ ១០ ដុល្លារអាមេរិក ដែលមានស្រាប់ សរុបគឺចំនួន ១៥ ដុល្លារអាមេរិក ក្នុងមួយខែជូនកម្មករនិយោជិត ។

THE ARBITRATION COUNCIL

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ហែម ប្អូណារិទ្ធ**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **រុន សារ៉ាយ**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL